ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែឧសភា ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែឧសភានេះ ការងារបង្កបង្កើនផលដំណាំរដូវវស្សាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសស្រូវរដូវវស្សាសម្រេចបាន ៨៧៤ ៦៤០ហ.ត ស្មើនឹង៣៣,៥២% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ វិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែឧសភានេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់តាមរយៈការប្រជុំពីចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗ ឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅ របស់រាជរដ្ឋាភិបាល ដែលសម្រេចបានគិតត្រឹមខែឧសភា ឆ្នាំ២០២១នេះ មានដូចតទៅៈ

## II- លទ្ធផលសម្រេចបានតាមបណ្ដាផ្នែក

### ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ១ ០៧២ ៥៣៦ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១ ៣៣៨ហ.ត ស្មើនឹង០,១២% និងដោយគ្រឿងយន្តចំនួន ១ ០៧១ ១៩៨ហ.ត ស្មើនឹង៩៩,៨៨%
- ផ្ទៃដីសាបសម្រេចបានចំនួន ១ ៣៨៤ហ.ត លើសឆ្នាំមុនចំនួន ៧៨៦ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៨៧៤ ៦៤០ហ.ត ស្មើនឹង៣៣,៥២% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត លើសឆ្នាំមុន ២៣៥ ៤៨២ហ.ត។

#### ១.២ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ២៣ ១២៤ហ.ត ស្មើនឹង៤៣,០៧% នៃផែនការចំនួន ៥៣ ៦៨៦ហ.ត តិចជាងឆ្នាំមុន ២ ០២៩ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៣៣៩ ៩៣៦ហ.ត ស្មើនឹង៤១.៤៦% នៃផែនការចំនួន ៨១៩ ៩៨៩ហ.ត លើសឆ្នាំមុន ១១ ៨១០ហ.ត។

#### ១.៤ ការនាំចេញផលិតផលកសិកម្ម

##### ១.៤.១ ការនាំចេញអង្ករ

- បរិមាណអង្ករនាំចេញរយៈពេល៥ខែមានចំនួន ២៣៣ ០៣១តោន ថយចុះចំនួន ១២៣ ០៦៦តោន (-៣៤,៥៦%) បើធៀបបរិមាណនាំចេញក្នុងរយៈពេល៥ខែឆ្នាំ២០២០ មានចំនួន ៣៥៦ ០៩៧តោន

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

- ការនាំចេញអង្ករក្នុងខែឧសភា ឆ្នាំ២០២១ មានចំនួន ៤០ ៥៣៦តោន ថយចុះចំនួន ១៥ ៣០៩តោន (-២៧,៤១%) បើធៀបខែឧសភា ឆ្នាំ២០២០ មានចំនួន ៥៥ ៨៤៥តោន

- អង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២០ប្រទេសមានបរិមាណសរុបចំនួន ៥៥ ១៨៨តោន (២៣,៦៦%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១២០ ៨៣៤តោន (៥១,៨៦%) ទិសដៅអាស៊ានចំនួន៥ប្រទេស មានបរិមាណសរុប ២១ ៨៤៨តោន (៩,៣៨%) និងទិសដៅផ្សេងទៀតចំនួន១៩ប្រទេសមានបរិមាណសរុប ៣៥ ១៦១តោន (១៥,១%)

- ក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន៥៤ក្រុមហ៊ុន ហើយបរិមាណអង្ករបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ១៦៨ ៥១១តោន (៧២,៣១%) និងក្រុមហ៊ុន៤៤ផ្សេងទៀតនាំចេញត្រឹមតែ ៦៤ ៥២០តោន (២៧,៦៩%)។

**១.៤.២ ការនាំចេញកសិផលផ្សេងៗ**

ក្នុងរយៈពេល៥ខែ ឆ្នាំ២០២១ មានបរិមាណៈ

- ដំឡូងមីស្រស់មានចំនួន ៣៣៩ ០០០តោន (ថយចុះចំនួន -៥,២០%) នាំចេញទៅប្រទេសថៃចំនួន ៦០ ០០០តោន និងប្រទេសវៀតណាមចំនួន ២៧៩ ០០០តោន

- ម្សៅដំឡូងមីមានចំនួន ១៣ ៤៥៤,៦៤តោន (កើនឡើងចំនួន ៣០,៩៧%) នាំចេញទៅប្រទេសចិនចំនួន ១២ ៨៤១តោន ប្រទេសអ៊ីតាលីចំនួន ៣៣,៨៤តោន ប្រទេសណេដឺឡែនចំនួន ១១៤តោន ប្រទេសថៃចំនួន ២៩៥,៨០តោន និងសហរដ្ឋអាមេរិកចំនួន ១៧០តោន

- គ្រាប់ស្វាយចន្ទីមានចំនួន ៨០១ ៧៣២,២៦តោន (កើនឡើងចំនួន ៣២១,៦៥%) នាំចេញទៅប្រទេសចិន ចំនួន ៣ ៥៦៦,៨៨តោន ប្រទេសឥណ្ឌាចំនួន ១៧តោន ប្រទេសជប៉ុនចំនួន ៣៣,៤៦តោន ប្រទេសឡាវចំនួន ២តោន ប្រទេសអារ៉ាប់ចំនួន ០,៥២តោន ប្រទេសថៃចំនួន ៣ ១០៨,៤០តោន និងប្រទេសវៀតណាមចំនួន ៧៩៥ ០០៤តោន

- គ្រាប់ពោតមានចំនួន ១៣៦ ៨៧៩,១៣តោន (កើនឡើងចំនួន ២៨៤,១០%) នាំចេញទៅប្រទេសបង់ក្លាដេស ចំនួន៤២តោន ប្រទេសកូរ៉េចំនួន ២១តោន កោះតៃវ៉ាន់ចំនួន ៦៧៦,១៣តោន ប្រទេសថៃចំនួន ៤២ ៣៥០តោន និង ប្រទេសវៀតណាមចំនួន ៩៣ ៧៩០តោន

- គ្រាប់សណ្ដែកបាយមានចំនួន ១៦ ៥៨០តោន (កើនឡើងចំនួន ៥១១,៨៦%) នាំចេញទៅប្រទេសវៀតណាម

- គ្រាប់សណ្ដែកសៀងមានចំនួន ១៦ ៧០០,០៤តោន (កើនឡើងចំនួន ១០០%) នាំចេញទៅប្រទេសថៃចំនួន ៦ ២៥០តោន ប្រទេសអារ៉ាប់រួមចំនួន ០,០៤តោន និងប្រទេសវៀតណាមចំនួន ១០ ៤៥០តោន

- ផ្លែចេកស្រស់មានចំនួន ២០៥ ០២៤,៤៧តោន (កើនឡើងចំនួន ៦៨,៨៦%) នាំចេញទៅប្រទេសចិនចំនួន ១៧៩ ០៩៦,៨១តោន ប្រទេសជប៉ុនចំនួន ៣៣៣,៨៤តោន ប្រទេសសិង្ហបុរីចំនួន ៤៨០,៤៨តោន និងប្រទេសវៀតណាម ចំនួន ២៥ ១១៣,៣៤តោន

- ផ្លែក្រូចថ្លុងមានចំនួន ២២ ៦១៨,៤៤តោន (កើនឡើងចំនួន ១២៨,៤៧%) នាំចេញទៅប្រទេសថៃចំនួន ២២ ៥៥៤តោន និងប្រទេសវៀតណាមចំនួន ៦៤,៤៤តោន

- ផ្លែស្វាយស្រស់មានចំនួន ១៥៦ ៧២៤,៥២តោន (កើនឡើងចំនួន ២៥៥,៣៩%) នាំចេញទៅហុងកុងចំនួន ៥០,៧៨តោន ប្រទេសកូរ៉េចំនួន ១២៤,៣៨តោន ប្រទេសគុយវ៉ែតចំនួន ០,០១តោន ប្រទេសសិង្ហបុរីចំនួន ១៦,២០តោន ប្រទេសថៃចំនួន ២០ ២១៩,២៨តោន ប្រទេសវៀតណាមចំនួន ១៣៦ ១០២,៦៥តោន និងប្រទេសចិនចំនួន ២១១,២២តោន

- ដូងប្រេងមានចំនួន ២១ ៨១៦,៦៨តោន (កើនឡើងចំនួន ៤១,៧៦%) នាំចេញទៅប្រទេសឥណ្ឌាចំនួន ១៨ ០១៦,៦៨តោន និងប្រទេសម៉ាឡេស៊ីចំនួន ៣ ៨០០តោន

- ម្រេចមានចំនួន ៧ ៤៦១,២១តោន (កើនឡើងចំនួន ១៩៩,២០%) នាំចេញទៅប្រទេសប៊ែលហ្ស៊ិកចំនួន៧,៥៦តោន សាធារណរដ្ឋឆែកចំនួន ៦,១០តោន ប្រទេសបារាំងចំនួន ១៣,៨៦តោន ប្រទេសអាល្លឺម៉ង់ចំនួន ៧០,៨២តោន ប្រទេស ឥណ្ឌាចំនួន ២៥តោន ប្រទេសជប៉ុនចំនួន ២,១៨តោន ប្រទេសកូរ៉េចំនួន ១,៣០តោន ប្រទេសប៉ូឡូញចំនួន ៧,០៩តោន ប្រទេសរុស្ស៊ីចំនួន ០,៣១តោន ប្រទេសស៊ុយអ៊ែតចំនួន ១,១៥តោន កោះតៃវ៉ាន់ចំនួន ១៥តោន ប្រទេសអង់គ្លេសចំនួន ១,២៤តោន ប្រទេសអារ៉ាប់រួមចំនួន ០,០១តោន សហរដ្ឋអាមេរិកចំនួន ១,១០តោន និងប្រទេសវៀតណាមចំនួន ៧ ៣០៨,៤៩តោន

- ថ្នាំជក់មានចំនួន ៨៧៩,៨៥តោន (ថយចុះចំនួន -៦៨,១៣%) នាំចេញទៅប្រទេសប៊ែលហ្ស៊ិកចំនួន ១៩,៨២តោន ប្រទេសអាល្លឺម៉ង់ចំនួន ០,០០១តោន ប្រទេសហុងគ្រីចំនួន ០,០១តោន ប្រទេសឥណ្ឌូនេស៊ីចំនួន ០,០២តោន ប្រទេស សិង្ហបុរីចំនួន ០,០០៥តោន និងប្រទេសវៀតណាម ៨៦០តោន

- បន្លែចម្រុះមានចំនួន ៣៦,៤៦តោន (ថយចុះចំនួន -៣៣,០៥%) នាំចេញទៅប្រទេសបារាំង

- ម្ទេសស្រស់មានចំនួន ៥៦ ៥០៧,១២តោន (កើនឡើងចំនួន ៩៤,៨៦%) នាំចេញទៅប្រទេសថៃចំនួន ៥៦ ៥០៧,១២តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០០២តោន

- ម្ទេសក្រៀមមានចំនួន ៦០០តោន (ថយចុះចំនួន -៥០%) នាំចេញទៅប្រទេសថៃ និងផលិតផលចំនួន ៥០មុខផ្សេងទៀតមានចំនួន ៧៤ ០២៩,២៩តោន។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ១៦០ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៩២ ៥០០ហ.ត ស្មើនឹង៧២% និងផ្ទៃដីថែទាំចំនួន ១១១ ៦៦០ហ.ត ស្មើនឹង២៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ១៦ ៨៧៨តោន កើនឡើងចំនួន ៤ ៤៤៩តោន ស្មើនឹង៣៦% ធៀបខែមុន និងថយចុះចំនួន ២ ០៨៣តោន ស្មើនឹង១១% ធៀបខែឧសភា ឆ្នាំ២០២០

- ផលិតផលឈើកៅស៊ូសម្រេចបានចំនួន ២៥០ម៣។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណជ័រកៅស៊ូបញ្ចេញលក់សម្រេចបានចំនួន ១៦ ០៧៩តោន កើនឡើងចំនួន ៩៩៥តោន ស្មើនឹង៦,៦០% ធៀបខែមុន និងថយចុះចំនួន ២ ៥៨៧តោន ស្មើនឹង១៤% ធៀបខែឧសភា ឆ្នាំ២០២០។

- បរិមាណបញ្ចេញលក់ឈើកៅស៊ូមានចំនួន ២៥០ម៣។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃជ័រកៅស៊ូលក់មធ្យមក្នុងខែឧសភាគឺ១ ៧៩២ដុល្លារ/តោន បានថយចុះចំនួន ៧ដុល្លារ/តោន ស្មើនឹង ០.៣៦% ធៀបខែមុន និងកើនឡើងចំនួន ៦០៥ដុល្លារ/តោន ស្មើនឹង៥១% ធៀបខែឧសភា ឆ្នាំ២០២០

- តម្លៃលក់ឈើកៅស៊ូមធ្យមក្នុងខែឧសភាគឺ១៦០ដុល្លា/ម៣ សម្រាប់ប្រភេទ S4S, តម្លៃ៤៩ដុល្លារ/ម៣សម្រាប់ប្រភេទ Finger Joint និងតម្លៃ២៨៩ដុល្លារ/ម៣ សម្រាប់ប្រភេទ Plywood

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែឧសភាគឺទឹកជ័រ (DRC គិតតាមភាគរយជ័រស្ងួត) មានការប្រែប្រួលពី ៥ ៦០០៛/គ.ក្រ ដល់ ៦ ០០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ១៥០៛/គ.ក្រ ដល់ ២ ៩៧៥៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បាននិងកំពុងពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២១ ព្រមទាំងបានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០២១ ចំនួន ១០ផ្ទាំង និងរូបភាពផ្កាយរណប Sentinel-2 ចំនួន ៥ផ្ទាំង

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ២០គ្រឿង និងយានយន្តចំនួន ២៧គ្រឿងជូនក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១នាក់។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃឆ្លោះទៅកាន់មាត់ច្រកអន្តរជាតិសម្រាប់នាំចេញចំនួន ៣ច្បាប់មានសត្វស្វាក្តាមចំនួន ១ ៦៧៨ ក្បាល

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៥ច្បាប់ សម្រាប់ការថែរក្សាត្រចៀកកាំមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ និងខេត្តកំពង់ចាម។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧កំពុងដំណើរការកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨ទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្តាមចំនួន ៨១ ៣៦៤ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៥ ៦៥២ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦៤០ក្បាល (បក្សីចំនួន ៥៨ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វព្រៃថ្មីចំនួន ២៣ក្បាល ព្យាបាលចំនួន ២៤ក្បាល និងបានស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ១៨ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ៣០នាក់ បានចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្ការក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវដោយក្រាលក្រួសក្រហមប្រវែង ៣៣០ម៉ែត្រ និងកាប់ឆ្ការធ្វើអនាម័យព្រៃទំហំ ១២ ០០០ម៉ែត្រការ៉េនៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បានដឹកប្រឡាយការពារចម្ការគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្ការព្រៃឈើអន្លង់ថ្មខេត្តកំពង់ធំប្រវែង ៥០០ម៉ែត្រ

- បាននិងកំពុងថែទាំចម្ការឈើសរុប ៨២២ហ.ត ក្នុងនោះចម្ការពូជឈើ ៩៤ហ.ត ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ ៤៤ហ.ត ចម្ការឈើដាំទំហំ ៦៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា ទំហំ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្ដាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- បានឈូសឆាយសម្អាតដីសម្រាប់ដាំឈើជាចម្ការទំហំ ២០ហ.ត នៅក្នុងខេត្តកំពង់ធំ

- បានបណ្ដុះកូនឈើគ្រប់ប្រភេទចំនួន ២៦ ៦៩០ដើម ថ្នាលបណ្ដុះកូនឈើចំនួន ៦កន្លែងស្ថិតក្នុងខេត្តចំនួន៥ គឺ៖ ខេត្តពោធិ៍សាត់ កំពង់ធំ តាកែវ កំពង់ចាម និងខេត្តកណ្ដាល២កន្លែង។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ១៨ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន៖ ឈើអារចំនួន ៤៥ម៣ ផ្ទៃដីព្រៃឈើកាប់រានទំហំ ២០ហ.ត ក្នុងខេត្តរតនគិរី និងខេត្តកំពង់ឆ្នាំង ព្រមទាំងអនុផលព្រៃឈើ និងឧបករណ៍ផ្សេងៗទៀត

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- បានចុះពិនិត្យសំណើសុំពន្យារសុពលភាពរោងសិប្បកម្មកែច្នៃចិញ្ច្រាំកម្ទេចឈើដាំចំនួន ១កន្លែងនៅក្នុងខេត្តបន្ទាយមានជ័យ

- ក្រុមហ៊ុនចំនួន៣បាននាំចេញទៅក្រៅប្រទេសនូវផលិតផលរានទេវតា និងឈើកែច្នៃមានបរិមាណចំនួន ១៩៣ម៣ និងជ័រទឹកចំនួន ២៤តោន

- ក្រុមហ៊ុនចំនួន១បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ១២៤ម៣

- បានផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១មានឈើកែច្នៃចំនួន ១៦៨ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- បានចំណូលពីផលព្រៃឈើចំនួន ៦២៨ ៧១១ ២៥០រៀល និង៣៩០ ១០២,៨៤ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្ដុះបណ្ដាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្ដាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្ដារាជធានី-ខេត្តរៀងរាល់សប្ដាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្ដល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិត-ផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ២ករណី។ រាជធានី-ខេត្តចំនួន ២៥

បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៤ ៧៣៩លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ពិនិត្យ និងកែសម្រួលលើឯកសារជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ចូលរួមផ្សព្វផ្សាយ និងទប់ស្កាត់ជំងឺផ្តាសាយបក្សី និងចុះផ្សព្វផ្សាយជំងឺឆ្លងសត្វនៅតាមបណ្តាខេត្ត។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ។

**៤.៣ ការងារស្រាវជ្រាវ**

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៤ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ១ ៨៨៣វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

**៥.១.១ នេសាទទឹកសាប**

- ដាយត្រីអនុវត្តពុំមាន សរុបរយៈពេល៥ខែចំនួន ១ ៣១០តោន ស្មើនឹង១១,៩១% នៃផែនការចំនួន ១១ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ ថយចុះចំនួន ១៩០តោន

- នេសាទគ្រួសារដែននេសាទអនុវត្តបានចំនួន ១៥ ៩០០តោន សរុបរយៈពេល៥ខែចំនួន ១១៣ ៤០០តោន ស្មើនឹង៣៧,៨០% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ កើនឡើងចំនួន ២ ២០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ២ ៧០០តោន សរុបរយៈពេល៥ខែចំនួន ១៨ ៩០០តោន ស្មើនឹង១៣,៥០% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ ថយចុះចំនួន ៦ ២០០តោន។

**៥.១.២ នេសាទសមុទ្រ**

អនុវត្តបានចំនួន ១០ ៣០០តោន សរុបរយៈពេល៥ខែចំនួន ៤៦ ២០០តោន ស្មើនឹង៣៥,៥៤% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ កើនឡើងចំនួន ២០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ១៥ ៩០០តោន សរុបរយៈពេល៥ខែចំនួន ១១៣ ០០តោន ស្មើនឹង២៣,៤៩% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ កើនឡើងចំនួន ៨ ៧០០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ១០ ៥០០ក្បាល សរុបរយៈពេល៥ខែចំនួន ៤៥ ៥០០ក្បាល ស្មើនឹង១៣,៧៩% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ ថយចុះចំនួន ១៦ ២០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ១៩ ៨០០ ០០០កូន សរុបរយៈពេល៥ខែចំនួន ៧១ ៨០០ ០០០កូន ស្មើនឹង២៦,៥៩% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ១ ០០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៤ ២០០តោន សរុបរយៈពេល៥ខែចំនួន ២១ ២១០តោន ស្មើនឹង២៦,៥១% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ ថយចុះចំនួន ១ ១៩០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ៣០០តោន សរុបរយៈពេល៥ខែចំនួន ៥ ៤២០តោន ស្មើនឹង៤៥,១៧% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ កើនឡើងចំនួន ២០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៤ ៤០០ ០០០លីត្រ សរុបរយៈពេល៥ខែចំនួន ២១ ៣៥០ ០០០លីត្រ ស្មើនឹង៣៨,៨២% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ ថយចុះចំនួន ៩៨០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ១១៥ករណី ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ ថយចុះចំនួន ៣២ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១១២ករណី និងសមុទ្រចំនួន ៣ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ២១៩តោន សរុបរយៈពេល៥ខែចំនួន ១ ៣១៦តោន ស្មើនឹង១៦,៤៥% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ កើនឡើងចំនួន ១៧៦តោន

- ផលនេសាទកែច្នៃនាំចេញពុំមាន សរុបរយៈពេល៥ខែចំនួន ១៤៧តោន ស្មើនឹង៧,៣៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀប ខែឧសភា ឆ្នាំ២០២០ ថយចុះចំនួន ៨៥តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលសេវាជលផលចំនួន ២៩ ០១៤ ០០០រៀល សរុបរយៈពេល៥ខែចំនួន ៣៧២ ៨៩៩ ៨៤៤រៀល ស្មើនឹង១០៣,៩៩% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបខែឧសភា ឆ្នាំ២០២០ កើនឡើងចំនួន ៣២ ៣៤៧ ៣៦៤រៀល។

## ៦ ផ្នែកអន្តរាធិការដ្ឋាន

- មិនបានចុះបំពេញបេសកកម្មតាមផែនការ ដោយសារមានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-19

- ការទទួលពាក្យបណ្ដឹងតាមរយៈប្រអប់សំបុត្រ និងតាមរយៈប្រព័ន្ធអ៊ិនធើណេតពុំមាន

- ស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ២១ករណី លើវិស័យព្រៃឈើ២ករណី ជលផល៣ករណី និងវិស័យផ្សេងៗ១៦ករណី ។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៥៦១ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២០០ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២៥៦ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១០៥ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ១៧៩ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរចំនួន ២១ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៣១ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំ ដើម្បីក្ដាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្ដាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨២៦នាក់ (ស្រី១ ៤១៥នាក់ ស្មើនឹង២៤,២៨%) រួមមាន៖
  + អង្គភាពថ្នាក់កណ្ដាលចំនួន ២ ៩១៤នាក់ (ស្រី៨២២នាក់ ស្មើនឹង២៨,១៩%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩១២នាក់ (ស្រី៥៩៣នាក់ ស្មើនឹង២០,៣៦%)

- បានរៀបចំប្រកាសផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ១នាក់

- បានរៀបចំប្រកាសស្ដីពីការផ្ទេរមន្ត្រីរាជការទៅក្រៅក្រសួងចំនួន ២នាក់

- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកសរុបចំនួន ៥នាក់ (ស្រី១នាក់) ក្នុងនោះ៖ ច្បាប់ឈប់សម្រាកលំហែមាតុភាព១នាក់ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំ១នាក់ ច្បាប់ឈប់សម្រាករយៈពេលខ្លី២នាក់ និងច្បាប់ឈប់សម្រាកព្យាបាលជំងឺ១នាក់

- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៦នាក់

- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលបម្រើការងារវិញចំនួន ៥នាក់
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ចំនួន ៧នាក់
- ការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ១៩នាក់ (ស្រី០៣នាក់)
    + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លីនិងមធ្យមចំនួន ១៥នាក់
    + ការបណ្តុះបណ្តាលក្រៅប្រទេសរយៈពេលខ្លី និងមធ្យម តាមរយៈប្រព័ន្ធអនឡាញ (Online) ចំនួន ៤នាក់។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានពិនិត្យ និងកែសម្រួលសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤
- បានចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងមួយសប្តាហ៍នូវរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តចំនួន២៥
- បានបញ្ចូលទិន្នន័យទៅក្នុងកុំព្យូទ័រ https://tmp.amis.org.kh ដើម្បីវិភាគទិន្នន័យសម្រាប់ធ្វើរ៉ៃយបត្រប្រចាំត្រីមាស ឆ្នាំ២០២១
- បានចូលរួមប្រជុំតាមប្រព័ន្ធវីដេអូអនឡាញស្តីពីការវាយតម្លៃចុងក្រោយជ្រើសរើសអ្នកទទួលផលនៃគម្រោងអន្តរាគមន៍បន្ទាន់ឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ១៩ ក្រោមគម្រោងពិពិធកម្មកសិកម្មកម្ពុជា
- បានពិភាក្សាកែលម្អការអនុវត្តឆ្នាំកន្លងមក និងពិនិត្យកែសម្រួលធ្វើបច្ចុប្បន្នភាពមេរៀន បញ្ជីសំណួរវគ្គបណ្តុះបណ្តាលដល់កសិករស្តីពី ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់បរិស្ថាន ក្នុងផលិតកម្មកសិកម្មនិងត្រៀមរៀបចំឯកសារ សម្ភារ លិខិតផ្លូវការផ្សេងៗសម្រាប់ចុះអនុវត្តនាពេលឆាប់ៗនេះ។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធ NRMIS សរុបទឹកប្រាក់ចំនួន ៣ ៧៦៩ ៤៣៨ ១៤០រៀល
- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៧៣០ ៨២១ ៣០០រៀល
- បានរៀបចំលិខិតស្តីពីការធ្វើវិចារណកម្មចំណាយថវិកាឆ្នាំ២០២១ ដោយកែសម្រួលថវិកាតាមកម្មវិធីអនុកម្មវិធីចង្កោមសកម្មភាព និងតាមប្រភេទចំណាយរបស់អង្គភាពថវិការដ្ឋបាលកណ្តាលក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានចូលរួមប្រជុំតាមអនឡាញ (កម្មវិធី Zoom) ជាមួយក្រុមការងារធនាគារពិភពលោកស្តីពីការកែសម្រួលនីតិវិធីអនុវត្តការងារដោយប្រើប្រាស់ប្រព័ន្ធ FMIS ទាំងស្រុង
- បានរៀបចំសំណើសុំអនុញ្ញាតនាំចូលរថយន្ត ២គ្រឿងដោយការបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋសម្រាប់អនុវត្តកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកនេសាទ (CaPFish-Capture) ក្រោមហិរញ្ញប្បទានឥតសំណងរបស់សហភាពអឺរ៉ុប
- បានរៀបចំឯកសារដេញថ្លៃ និងឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីដំណើរការអនុវត្តនៃកិច្ចលទ្ធកម្មលើការផ្គត់ផ្គង់សម្ភារបរិក្ខារពិសោធន៍របស់អគ្គនាយកដ្ឋានកសិកម្ម
- បើកសំណើដេញថ្លៃការផ្គត់ផ្គង់ថ្នាំចាក់ការពារ និងព្យាបាលសត្វប្រចាំឆមាសទី១ ឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤
- បានធ្វើវិចារណកម្មចំណាយលើឥណទានអនុម័តឆ្នាំ២០២១
- បានធ្វើវិចារណកម្មចំណាយលើឥណទានរដ្ឋទេយ្យបុរេប្រទានកម្មវិធីឆ្នាំ២០២១
- ពុំបានចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ ដោយសារស្ថានភាពឆ្លងរាលដាលនៃជំងឺកូវីដ-19។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចូលរួមកិច្ចប្រជុំ៦លើក សិក្ខាសាលា២លើក ទស្សនកិច្ច១លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី

- បានចូលរួមសិក្ខាសាលា (តាមប្រព័ន្ធវីដេអូពីចម្ងាយ) ចំនួន ១លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស

- បានសម្របសម្រួលកិច្ចប្រជុំចំនួន ៣លើកលើការងារក្នុងប្រទេស

- បានសម្របសម្រួលការចុះកិច្ចព្រមព្រៀងគម្រោង WCPO ស្តីពីការពង្រីកការអភិរក្ស និងគាំពារសុខភាពសត្វព្រៃនៃព្រះរាជាណាចក្រកម្ពុជាដោយគិតជាទឹកប្រាក់ចំនួន ១៣៣ ១០៤ដុល្លារ

- បានសម្របសម្រួលការចុះកិច្ចព្រមព្រៀងគម្រោង APAARI PA ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការសម្រាប់ការស្រាវជ្រាវកសិកម្មនវានុវត្តន៍ និងការអប់រំកសិកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកដោយគិតជាទឹកប្រាក់ចំនួន ២០ ០០០ដុល្លារ។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២២ក្រុមហ៊ុន សរុបចំនួន ២៣៧មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៤ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៦ក្រុមហ៊ុន សរុបចំនួន ៤៨សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

បានពិនិត្យ និងផ្តល់មតិចំនួន ១ករណី។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១ក្រុមហ៊ុន

- ពិនិត្យការស្នើសុំចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្ម និងលាយផ្សំវេចខ្ចប់ជាថ្មីចំនួន ១ក្រុមហ៊ុន។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ដកស្រង់ព័ត៌មានកសិកម្មប្រចាំថ្ងៃចេញពីបណ្តាញផ្សព្វផ្សាយសារព័ត៌មានសរុបចំនួន ១៣៧ព័ត៌មាន

- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសរុបចំនួន១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត

- តាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តលើគេហទំព័រសរុបចំនួនផុស ២៧១ព័ត៌មាន

- តំឡើងប្រព័ន្ធ Firewall សម្រាប់ម៉ាស៊ីនមេដើម្បីការពារការលុកចូលពីខាងក្រៅ (Hacker)

- បណ្ណាល័យកសិកម្ម បានទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តីដែលទទួលបានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ៥ក្បាល/ច្បាប់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្តីពីការជោគជ័យលើមុខរបរចិញ្ចឹមឃ្មុំនៅខេត្តត្បូងឃ្មុំ និងមុខរបរបង្កាត់ពូជមាន់ស្រែលក់ យកកូនលក់របស់កសិករនៅខេត្តកណ្តាល

- បានចុះទៅថត Video បទយកការណ៍ចំនួន ២ប្រធានបទ

- បានចាក់ផ្សាយឡើងវិញស្តីពីវេទិកាស្វែងយល់ពីកសិកម្មចំនួន ២ប្រធានបទ

- បានចាក់ផ្សាយឡើងវិញស្តីពីនាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ

- បានផ្សព្វផ្សាយអត្ថបទបច្ចេកទេសកសិកម្មស្តីពីបច្ចេកទេសដាំដំណាំខ្ទឹមស ខាត់ណាដើម ការចិញ្ចឹមគោ សៀវភៅណែនាំជំងឺបូលខ្យល់សត្វគោក្របី ការចិញ្ចឹមបង្កង ការចិញ្ចឹមជ្រូក។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពី របាយការណ៍សិក្សាការវាយតម្លៃលើផលប្រយោជន៍នៃការធ្វើកិច្ចសន្យាផលិតកម្មកសិកម្មតាមរយៈប្រព័ន្ធអនឡាញ

- បានចូលរួមប្រជុំស្តីពី Cooperation on grievance mechanism for contract farming

- បានចូលរួមវគ្គបណ្តុះបណ្តាលតាមប្រពន្ធ័អនឡាញស្តីពីការអនុវត្តមន្ទីរពិសោធន៍ល្អ (Good Laboratory Practice, GLP) ដែលរៀបចំដោយគម្រោង អាស៊ីប៉ាស៊ីហ្វិក (Standard Trade Development Facility, STDF)

- បានចូលរួមវគ្គបណ្តុះបណ្តាលមន្ទីរពិសោធន៍និម្មិតតាមប្រព័ន្ធ Online ស្តីពីការប្រមូលសំណាកការរៀបចំប្រើប្រាស់ទុកដាក់សំណាក ការលាងសម្អាត និងការវិភាគកាកសំណល់ថ្នាំកសិកម្ម និងការធ្វើបង្ហាញក្នុងមន្ទីរពិសោធន៍តាមវីដេអូ

- បានធ្វើការវិភាគធ្វើតេស្តលើសំណាកត្រីទឹកសាបចំនួន ១៤ប្រភេទ ក្នុងនោះ វិភាគធ្វើតេស្តរកកាកសំណល់លោហៈធ្ងន់គឺ អាសេនិច (Arsenic, As) សំណ (Lead, Pb) និងបារត (Mercury, Hg) វិភាគធ្វើតេស្តរកសមាសធាតុគីមីគឺ ខ្លាញ់សរុប (Crude Fat) ហ៊ីស្តាមីន (Histamine) វិភាគធ្វើតេស្តរកវត្តមានបាតេរីបង្កគ្រោះថ្នាក់គឺ បាក់តេរីសរុប (Total Plate count) សាល់ម៉ូណេឡា (Salmonella) និងអ៊ីកូលី (E-coli)

- បានវិភាគធ្វើតេស្តសំណាកទឹកឃ្មុំចំនួន ២ប្រភេទ ក្នុងនោះ វិភាគធ្វើតេស្តសមាសធាតុគីមីគឺ សំណើម (Moisture) ផេះ (Ash) អាស៊ីត (Acid/pH) វិភាគធ្វើតេស្តរកវត្តមានបាតេរីបង្កគ្រោះថ្នាក់គឺ បាក់តេរីសរុប (Total Plate count) មេតំបែ និងផ្សិត (yeast and mold) សាល់ម៉ូណេឡា (Salmonella) និងអ៊ីកូលី (E-coli)

- បានវិភាគធ្វើតេស្តសំណាក ម្សៅត្រីចំនួន ២ប្រភេទ និងចំណីត្រីចំនួន ១ប្រភេទ ក្នុងនោះ វិភាគធ្វើតេស្តរកកាកសំណល់លោហៈធ្ងន់អាសេនិច (Arsenic) វិភាគធ្វើតេស្តសមាសធាតុគីមីគឺ សំណើម (Moisture) ផេះ (Ash) ប្រូតេអ៊ីន (Crude protein) អាសូត( Nitrogen) ខ្លាញ់សរុប (Crude fat) អំបិល (Salt) ស្ករសរុប(Total sugar) សូដ្យូម(Na) កាល់ស្យូម (Ca) ផូស្វ័រ (P) វិភាគធ្វើតេស្តរកវត្តមានបាតេរីបង្កគ្រោះថ្នាក់គឺ បាក់តេរីសរុប (Total Plate count) មេតំបែ និងផ្សិត (yeast and mold) សាល់ម៉ូណេឡា (Salmonella) និងអ៊ីកូលី (E-coli)។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចូលរួមប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ដើម្បីបន្តពិនិត្យមតិ និងយោបល់សេចក្តីព្រាងឯកសារការអភិវឌ្ឍផែនទីតម្រង់ទិសរយៈពេល៥ឆ្នាំរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព តាមរយៈប្រព័ន្ធ online

- ចូលរួមវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីដំណើរការ និងការអនុវត្តឧបករណ៍ការពារផលប៉ះពាល់បរិស្ថាន និងសង្គម តាមប្រព័ន្ធ online

- បានចុះសម្ភាសន៍ស្តីពីការយល់ដឹងរបស់កសិករអំពីជីជាតិដីនៅខេត្តកំពង់ស្ពឺ

- បានចុះត្រួតពិនិត្យការងារពិសោធន៍នៅខេត្តព្រះវិហារ

- បានចុះត្រួតពិនិត្យការងារពិសោធន៍ និងបើកវគ្គបណ្តុះបណ្តាលនៅខេត្តព្រៃវែង ត្បូងឃ្មុំ និងសៀមរាប

- បន្តបញ្ចូលទិន្នន័យវិភាគលទ្ធផលពិសោធន៍ជាបណ្តើរៗ

- ចូលរួមសិក្ខាសាលាស្តីពីការពិនិត្យ ផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍លទ្ធផលនៃការសិក្សាខ្សែច្រវាក់តម្លៃផលិតផលកសិកម្មតាមប្រព័ន្ធ online។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- គ្រប់មហាវិទ្យាល័យថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងសាលាក្រោយឧត្តម នៅតែបន្តដំណើរការនៃការបង្រៀននិស្សិត

ពីចំងាយតាមរយៈប្រព័ន្ធអេឡិចត្រូនិក (Online)

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពី ១.ការធានាគុណភាពអប់រំផ្ទៃក្នុងសាកលវិទ្យាល័យ (IQA) ដោយសហការជាមួយ SEARCA-ហ្វីលីពីន ២.កសិកម្មអភិរក្ស និងការប្រើប្រាស់គ្រឿងយន្តកសិកម្មសម្រាប់កសិកម្មអភិរក្ស ៣.សិក្ខាសាលាវិទ្យាសាស្ត្ររបស់មជ្ឈមណ្ឌល ECOLAND

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ទឹកអូហ្សូនសម្អាតបន្លែ ផ្លែឈើ និងប្រសិទ្ធភាពរបស់វា ដែលធ្វើបទបង្ហាញដោយក្រុមហ៊ុន Cast, co.ltd នៃសាធារណរដ្ឋកូរ៉េ

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការផ្គត់ផ្គង់ផលិតផលកសិកម្ម និងពាណិជ្ជកម្មសម្រាប់ផ្លូវ១ ខ្សែក្រវ៉ាត់១ រៀបចំដោយសាធារណរដ្ឋប្រជាមានិតចិនដែលមានសិក្ខាកាមចូលរួម ១២ប្រទេស

- សាស្ត្រាចារ្យ និងនិស្សិតនៃមហាវិទ្យាល័យនិមួយៗ បាននិងកំពុងបន្តការងារសិក្សាពិសោធន៍ស្រាវជ្រាវលើប្រធានបទរៀងៗខ្លួន នៅក្នុងសាកលវិទ្យាល័យ និងនៅមូលដ្ឋានផលិតកម្មផ្សេងៗ។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ១ ១២៧នាក់ (ស្រី៤៦៤នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និង ភាសាអង់គ្លេស

- និស្សិតនៅប្រទេសអ៊ីស្រាអែលចំនួន ៤១នាក់ (ស្រី២២នាក់) និងនិស្សិតចំនួន ២២ (ស្រី២នាក់) បានវិលត្រឡប់មកកម្ពុជាវិញហើយ

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗដែលកំពុងដំណើរការ គឺការពិសោធន៍ចិញ្ចឹមគោទឹកដោះ ការពិសោធន៍ចិញ្ចឹមបង្គា ការពិសោធន៍បង្កាត់ពូជមាន់ ការសិក្សាពិសោធន៍ថ្នាំបណ្តេញសត្វល្អិត ការពិសោធន៍ចិញ្ចឹមពពែនៅតំបន់ភ្នំ ការសិក្សាស្រាវជ្រាវបង្កាត់កេសរកូល ការពិសោធន៍ដំណាំព្រីង ការសិក្សាពិសោធន៍ផលិតម្សៅឫស្សី ការបណ្តុះជាលិការុក្ខជាតិ ការពិសោធន៍ចិញ្ចឹមកង្កែប សាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធន៍ចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ ការសិក្សាផលិតកម្ម និងច្រវ៉ាក់តម្លៃស្វាយចន្ទី

- ចូលរួមវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធ Online ស្តីពី Radiation Technology for Industry

- ចូលរួមសិក្ខាសាលាតាមប្រព័ន្ធ Online ស្តីពី Cooperation in animal epidemic prevention and control និង Food security for development country

- បានទៅកាន់ខេត្តព្រៃវែងដើម្បីពិនិត្យការពិសោធន៍ដំណាំស្រូវពូជនាំចូលពីប្រទេសជប៉ុន ដែលអនុវត្តគម្រោងដោយដៃគូអភិវឌ្ឍន៍របស់វិទ្យាស្ថាន

- បាន និងកំពុងសាងសង់ SMART FARM។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៥៨៨នាក់ (ស្រី២៦៨នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- ពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច

- បានបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងវិភាគបាក់តេរីនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍ក្លូន កូនកៅស៊ូសុីដលីង ច្បារបង្កាត់ពូជ

- សហការជាមួយអង្គការ WWF-កម្ពុជា ក្នុងការរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រកៅស៊ូ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការយកផលទឹកជ័រកៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី

- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ និងស្រង់ទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍

- រៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នាដើម្បីលាបរំញោចតាមពិធីសាពិសោធន៍

- ស្រង់ទិន្នន័យដើមចៀរជ័របានចំនួន ៧ចម្ការពិសោធន៍

- អនុវត្តការថែទាំកៅស៊ូគ្រប់ចម្ការពិសោធន៍

- អនុវត្តការថែទាំកូនកៅស៊ូនៅថ្នាលបណ្តុះកូនឆ្នាំ២០២០-២០២១

- ត្រួតពិនិត្យការប្រមូលផលជ័រកៅស៊ូ និងការកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រ

- ធ្វើតេស្តកៅស៊ូចំនួន ៦សំណាកដើម្បីវាយតម្លៃគុណភាពនៃការកែច្នៃតាមស្តង់ដា CSR។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ៨៧៤ ៦៤០ហ.ត ស្មើនឹង៣៣,៥២% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើស ចលនាសត្វឈើក្នុងតំបន់ផ្ទះដំរី បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០២១

- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩

- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្ដាខេត្តដែលមានសក្ដានុពលកៅស៊ូ។

## ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្ដែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្ដារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកគ្រុចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្គុរ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្ដាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្ដីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្ដុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្ដុះបណ្ដាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្ដីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្ដីជូនដំណឹងលេខ១៣៤៨ សជណ.កធ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្ដារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្ដុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្ដីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃ ចន្ទ ១២ រោច ខែ ជេស្ឋ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**